
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

Kids of Destiny®
Reaching the Next Generation

## 3.07 ព្រះយេស៊ូវព្យាបាលមនុស្ស

ព្រះយេស៊ូវនិងអ្នកដើរតាមទ្រង់មិនបានរស់នៅកន្លែងតែមួយទេ។ ពួកគេមិនមានផ្ទះទេ ពួកគេធ្វើដំណើរគ្រប់ពេល ជារៀងរាល់ថ្ងៃពួកគេមានអាហារគ្រប់គ្រាន់ដែលពួកគេត្រូវការ។ រៀងរាល់យប់ពួកគេមានកន្លែងគេង។ ព្រះទ្រង់តែងតែប្រាកដថា ពួកគេមានអ្វីគ្រប់យ៉ាងដែលពួកគេត្រូវការ។ តាមវិធីនេះព្រះយេស៊ូវអាចធ្វើដំណើរពីក្រុងមួយទៅក្រុងមួយដើម្បីបង្រៀន និងព្យាបាលមនុស្ស ។

ថ្ងៃមួយព្រះយេស៊ូវ និងអ្នកដើរតាមទ្រង់បាននៅក្រុងយេរីខូ។ នៅពេលដែលពួកគេធ្វើដំណើរតាមផ្លូវមានមនុស្សជាច្រើនដើរតាមពួកគេ។ មានបុរសម្នាក់នៅក្បែរផ្លូវឈ្មោះបាទីមេ។ គាត់មើលមិនឃើញទេ គាត់ពិការភ្នែក។ ប៉ុន្តែគាត់អាចស្តាប់បាន។ គាត់បានលឺ ប្រជាជននិយាយអំពីព្រះយេស៊ូវដូច្នេះគាត់ស្រែកឡើងថា៖ «ឱព្រះយេស៊ូអើយ! សូមអាណិតមេត្តាខ្ញុំផង!″ ប្រជាជនបានប្រាប់គាត់ឱ្យនៅស្ងៀម ហើយមិនឱ្យរំខានដល់ព្រះយេស៊ូវឡើយ។ ប៉ុន្តែគាត់ស្រែកកាន់តែខ្លាំងឡើងៗថា៖ «ឱព្រះយេស៊ូអើយ! សូមអាណិតមេត្តាខ្ញុំផង!″

ព្រះយេស៊ូក៏ឈប់នៅតាមផ្លូវហើយមានព្រះបន្ទូលថា៖ «សុំយកគាត់មកឯខ្ញុំ»។ ប្រជាជននិយាយទៅកាន់លោកបាទីមេថា៖ «សប្បាយចិត្តឡើង! ព្រះយេស៊ូវកំពុងតែហៅអ្នកហើយ″ បាទីមេបានលោតឡើងហើយមករកព្រះយេស៊ូវ។ ព្រះយេស៊ូវសួរគាត់ថាតើគាត់ចង់បានអ្វី ‶ ខ្ញុំចង់ឃើញ″ គាត់តបដូច្នេះ។ ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា៖ «ទៅចុះ! ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ″ ភ្លាមៗនោះបាទីមេអាចមើលឃើញភ្លាម។ នៅថ្ងៃមួយទៀតព្រះយេស៊ូកំពុងធ្វើដំណើរម្តងទៀត ។ នៅពេលដែលទ្រង់ទៅជិតភូមិមួយតាមផ្លូវរបស់គាត់ទៅក្រុងយេរូសាឡិមមានបុរសដប់នាក់ដែលឈរនៅឆ្ងាយពីទ្រង់។ បុរសទាំងនេះមានរោគឃ្លង់។ រោគឃ្លង់ជាជំងឺស្បែកធ្ងន់ធ្ងរ។ នៅគ្រានោះបើអ្នកកើតឃ្លង់អ្នកត្រូវនៅឲ្យឆ្ងាយពីមនុស្សដែលមានសុខភាពល្អ។ ព្រោះពួកគេអាចឆ្លងជំងឺឃ្លង់បាន។ បុរសទាំងនេះបានលឺអំពីព្រះយេស៊ូវ និងរបៀបដែលទ្រង់ព្យាបាលមនុស្ស។ គេស្រែកឡើង ថា៖ «ឱព្រះយេស៊ូអើយ! សូមអាណិតមេត្តាយើងខ្ញុំផង! »។

ព្រះយេស៊ូវទ្រង់តែងតែត្រៀមខ្លួនជាស្រេចដើម្បីព្យាបាលមនុស្ស។ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅគេថា៖ «ចូរអ្នករាល់គ្នាទៅបង្ហាញខ្លួនឱ្យពួកបូជាចារ្យឃើញចុះ»។ (អាចារ្យធ្វើការនៅឯព្រះវិហារដែលមនុស្សគោរពបូជា។ ពួកគេនឹងបញ្ជាក់ថាបុរសទាំងនោះពិតជាបានជាសះស្បើយ ហើយមានសុវត្ថិភាពក្នុងការត្រឡប់ទៅផ្ទះវិញ)។ ភ្លាមៗនោះបុរសដែលកើតឃ្លង់បានជាសះស្បើយ។ ពួកគេបានដើរទៅដោយរីករាយ។ បន្ទាប់មកបុរសម្នាក់បានត្រឡប់មកវិញ។ គាត់បានឃើញថាគាត់បានជាសះស្បើយហើយក៏មានអំណរ និងសរសើរតម្កើនព្រះ។ គាត់បានក្រាបចុះនៅទៀបព្រះបាទាព្រះយេស៊ូវ ហើយអរព្រះគុណព្រះអង្គ។ ព្រះយេស៊ូវមានបន្ទូលថា ‶មានបុរស ១០ នាក់បានជា តែអ្នកជាមនុស្សតែម្នាក់គត់ដែលត្រឡប់មកវិញហើយថ្លែងអំណរគុណចំពោះការជាសះស្បើយ? ចូរទៅចុះ។ ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ។″

នៅក្នុងរឿងទាំងពីរនេះអ្នកដែលត្រូវការ ការព្យាបាល បានទូលសូមព្រះយេស៊ូវឱ្យអាណិតមេត្តាពួកគេ ។ សេចក្តីមេត្តាករុណាបាននាំព្រះពរដល់ពួកគេ ដូចជាអំណោយមួយដែលពួកគេមិនបានខំប្រឹងរកវាឡើយ ។ សេចក្តីមេត្តាករុណាគឺជាសេចក្តីល្អមួយមកពីព្រះអម្ចាស់ ពីព្រោះទ្រង់ស្រឡាញ់ពួកគេ ។ នៅក្នុងរឿងទាំងពីរនេះព្រះយេស៊ូវបានប្រោសគេឱ្យជា ។ ទ្រង់បានមានបន្ទូលថា ‶ទៅចុះជំនឿរបស់អ្នកបានជួយសង្គ្រោះអ្នកហើយ″

ដោយសារពួកគេជឿដោយគ្មានការសង្ស័យព្រះយេស៊ូវបានហៅថា ‶សេចក្តីជំនឿ″ យើងក៏អាចអំពាវនាវរកព្រះយេស៊ូវដោយសេចក្តីជំនឿដែរ ហើយទ្រង់នឹងស្តាប់យើងជានិច្ច ។

**ម៉ាកុស ១០ និង លូកា ១៧**

## 3.07 ព្រះយេស៊ូវព្យាបាលមនុស្ស - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន
## កំណត់សំគាល់

១) ព្រះយេស៊ូវ និងអ្នកដើរតាមទ្រង់មិនមានផ្ទះសម្រាប់រស់នៅទេ។ ពួកគេធ្វើដំណើរពីក្រុងមួយទៅក្រុងមួយដើម្បីបង្រៀន និងព្យាបាលមនុស្ស។ ព្រះបានប្រទានអ្វីៗទាំងអស់ដែលពួកគេត្រូវការ។

២) នៅក្នុងរឿងទីមួយបាទីមេជាមនុស្សខ្វាក់។ គាត់ដឹងថា ព្រះយេស៊ូវយាងមកតាមផ្លូវក្បែរកន្លែងដែលគាត់កំពុងអង្គុយ។ គាត់បានស្រែកសុំសេចក្តីមេត្តាករុណា។ គាត់ចង់មើលឃើញ ព្រះយេស៊ូវក៏បានព្យាបាលគាត់។ ព្រះយេស៊ូវមានបន្ទូលប្រាប់បាទីមេថា៖ «ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ»។

៣) នៅក្នុងរឿងទី២ មានបុរស ១០ នាក់ដែលមានជំងឺស្បែកធ្ងន់ធ្ងរហៅថារោគឃ្លង់។ ពួកគេក៏បានស្រែករកសេចក្តីមេត្តាករុណាផងដែរ។ ព្រះយេស៊ូវក៏បានព្យាបាលពួកគេដែរ។ នៅពេលដែលបុរសទាំងនោះបានចេញទៅយ៉ាងរីករាយបន្ទាប់ពីបានជាសះស្បើយ មានបុរសម្នាក់បានត្រឡប់មកវិញ។ គាត់បានត្រឡប់មកវិញហើយបានលុតជង្គង់នៅព្រះបាទាព្រះយេស៊ូវដោយអរគុណដល់ទ្រង់ដែលបានប្រោសគាត់ឱ្យជា។ ព្រះយេស៊ូវមានព្រះបន្ទូលថា៖ «ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ»។

៤) សេចក្តីមេត្តាករុណាគឺជាសេចក្តីល្អរបស់ព្រះ ទ្រង់ប្រទានដល់យើងពីព្រោះទ្រង់ស្រឡាញ់យើង។ យើងមិនធ្វើការដើម្បីទទួលបានវាទេ។ យើងមិនអាចរកវាបានទេ ប៉ុន្តែយើងអាចទូលសុំពីទ្រង់បាន។

៥) ជំនឿគឺជាការជឿដោយគ្មានការសង្ស័យ។ យើងអាចអធិស្ឋានរកព្រះយេស៊ូវដោយជំនឿ។ ទ្រង់នឹងស្តាប់យើងជានិច្ច។

### សំណួរ

១) តើព្រះយេស៊ូវ និងអ្នកដើរតាមទ្រង់រស់នៅយ៉ាងដូចម្តេច?
២) ហេតុអ្វីបានជាបារទីមេយំស្រែករកព្រះយេស៊ូវ?
៣) តើមានបុរសប៉ុន្មាននាក់បានស្រែករកព្រះយេស៊ូវដើម្បីសុំទ្រង់ព្យាបាលពីរោគឃ្លង់?
៤) តើមានបុរសប៉ុន្មាននាក់បានត្រលប់មកថ្លែងអំណរគុណបន្ទាប់ពីបានជាពីរោគឃ្លង់?
៥) តើព្រះយេស៊ូវបានមានបន្ទូលអ្វីទៅបាទីមេ និងបុរសម្នាក់ដែលបានជាពីរោគឃ្លង់?
៦) តើជំនឿជាអ្វី?

### ចម្លើយ

១) ព្រះយេស៊ូវ និងអ្នកដើរតាមព្រះអង្គបានធ្វើដំណើរពីក្រុងមួយទៅក្រុងមួយ។ ព្រះបានប្រទានអ្វីៗទាំងអស់ដែលពួកគេត្រូវការដើម្បីរស់នៅ។
២) បារទីមេបានស្រែករកព្រះយេស៊ូវពីព្រោះគាត់ចង់មើលឃើញ។
៣) បុរស ១០ នាក់បានស្រែករកព្រះយេស៊ូវដើម្បីសុំទ្រង់ព្យាបាលឱ្យជាពីរោគឃ្លង់។
៤) មានបុរសតែម្នាក់គត់បានមកអរគុណព្រះយេស៊ូវដែលបានប្រោសគាត់ឱ្យជាពីរោគឃ្លង់។
៥) ព្រះយេស៊ូវមានព្រះបន្ទូលទៅកាន់បាទីមេនិងបុរសដែលបានជាពីរោគឃ្លង់ថា៖ «ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ»
៦) ជំនឿគឺជាការជឿដោយគ្មានការសង្ស័យ។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org